**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ៤៣៤/២០ **ក.ប**/ប្រ.ក.ខ.ល

# ប្រកាស
# ស្តីពី
# ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ការអនុវត្តលក្ខខណ្ឌការងារល្អនៅក្នុងរោងចក្រ សហគ្រាស ដែលស្ថិតនៅក្រោមដែនអនុវត្តនៃច្បាប់ស្តីពីការងារ សំដៅបង្កើតឱ្យមានវប្បធម៌នៃអនុលោមភាពលក្ខខណ្ឌការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការផ្តល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារប្រចាំរោងចក្រ សហគ្រាស។

**ប្រការ២ .-**

វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ សំដៅដល់វិញ្ញាបនបត្រ ដែលចេញដោយអធិការការងារជូនដល់រោងចក្រ សហគ្រាស តាមវដ្តនៃការចុះអធិការកិច្ចការងារប្រចាំឆ្នាំ ឬតាមសំណើរបស់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ដើម្បីបញ្ជាក់អំពីស្ថានភាពលក្ខខណ្ឌការងារប្រចាំរោងចក្រ សហគ្រាសទាំងនោះបន្ទាប់ពីការចុះអធិការកិច្ចការងារ។

លក្ខណវិនិច្ឆ័យក្នុងការទទួលបានវិញ្ញាបនបត្រនេះ មានដូចខាងក្រោម៖

- មានការអនុវត្តលក្ខខណ្ឌការងារបានត្រឹមត្រូវ ស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- មានការអនុវត្តសេរីភាពអង្គការវិជ្ជាជីវៈបានត្រឹមត្រូវ ស្របតាមច្បាប់ស្តីពីសហជីព និងមានទំនាក់ទំនងវិជ្ជាជីវៈល្អ
- មានការអនុវត្តវិធានសុវត្ថិភាពនិងសុខភាពការងារបានត្រឹមត្រូវ ស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- មានការអនុវត្តនិងការបំពេញបែបបទស្តីពីសហគ្រាសបានត្រឹមត្រូវ
- មិនមានការប្រើប្រាស់ការងារកុមារដោយគ្មានការអនុញ្ញាតពីអធិការការងារ
- មានកម្មវិធីលើកកម្ពស់ផលិតភាព/សមត្ថភាពកម្មករនិយោជិត។

**ប្រការ៣ .-**

ត្រូវបានបង្កើតគណៈកម្មការផ្តល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ ជាសេនាធិការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការត្រួតពិនិត្យលក្ខណវិនិច្ឆ័យ ដូចមានចែងក្នុងប្រការ២ខាងលើ និងផ្តល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ ដោយផ្អែកលើរបាយការណ៍ស្តីពីអធិការកិច្ចការងារ និង/ឬ របាយការណ៍វាយតម្លៃលក្ខខណ្ឌការងារ ដែលរោងចក្រ សហគ្រាសផ្តល់ជូនដើម្បីធ្វើការត្រួតពិនិត្យ។

សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការផ្តល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៤ .-**

ប្រកាសលេខ២៦៨. សកបយ. ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការផ្តល់វិញ្ញាបនប័ត្រអនុវត្តច្បាប់ស្តីពីការងារចំពោះសហគ្រាស គ្រឹះស្ថាន និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធាននាយកដ្ឋានពេទ្យការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២ រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
  ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ